GC LiFE

# GC ការពារក្រេឌីត



## តើអ្វីទៅជា GC ការពារក្រេឌីត?

GC ការពារក្រេឌីត គឺជាគម្រោងធានារ៉ាប់រងដែលផ្តល់ការការពារលើឥណទានរបស់លោកអ្នក ក្នុងករណីមរណភាព និងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។ គម្រោងនេះធានាបានថាគ្រួសាររបស់លោកអ្នកនឹងមិនមានទុក្ខកង្វល់ក្នុងការសងបំណុលឡើយ ប្រសិនបើមានគ្រោះអកុសលណាមួយកើតឡើង។

## កម្មវត្ថុនៃការធានារ៉ាប់រង

អាយុជីវិតនៃអ្នកត្រូវបានធានារ៉ាប់រង។

## លក្ខណៈនៃផលិតផល

| | |
|---|---|
| អាយុអ្នកត្រូវបានធានារ៉ាប់រង | ចាប់ពី 18 ដល់ 64ឆ្នាំ |
| រយៈពេលធានារ៉ាប់រង | 1 - 30ឆ្នាំ |
| ទឹកប្រាក់ត្រូវបានធានា | ចាប់ពី $1,000ឡើង |
| ប្រភេទនៃទឹកប្រាក់ត្រូវបានធានា | ប្រភេទថេរ ឬប្រភេទថយចុះ |

● ប្រភេទថេរ មានន័យថាទឹកប្រាក់ត្រូវបានធានានៅរក្សាចំនួនថេរដដែលក្នុងអំឡុងពេលធានារ៉ាប់រង។

● ប្រភេទថយចុះ សំដៅទៅលើទឹកប្រាក់ត្រូវបានធានាដែលនឹងត្រូវថយចុះជារៀងរាល់ឆ្នាំនៅថ្ងៃខួបនៃបណ្ណសន្យារ៉ាប់រង។

## លក្ខខណ្ឌនៃការបង់បុព្វលាភ

| | |
|---|---|
| វិធីសាស្ត្របង់បុព្វលាភ | បង់ម្តងផ្តាច់ |
| មធ្យោបាយបង់បុព្វលាភ | ការផ្ទេរប្រាក់តាម App ឬគណនីធនាគារ សាច់ប្រាក់ មូលប្បទានបត្រ |
| ការបំពាន | មិនអនុវត្ត |

## វិសាលភាពនៃការធានារ៉ាប់រង

ផលិតផលនេះធានាទៅលើការទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រងក្នុងអំឡុងពេលដែលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព។

## អត្ថប្រយោជន៍ធានារ៉ាប់រង

### សំណងមរណភាព

**100%** នៃទឹកប្រាក់ត្រូវបានធានានឹងត្រូវផ្តល់ជូន ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព

### សំណងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

**100%** នៃទឹកប្រាក់ត្រូវបានធានានឹងត្រូវផ្តល់ជូន ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងទទួលរងពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍

## ករណីមិនធានា

**១. មរណភាព**

មិនមានអត្ថប្រយោជន៍លើមរណភាពនឹងត្រូវផ្តល់ជូននោះទេ ប្រសិនបើមរណភាពរបស់អ្នកត្រូវបានធានារ៉ាប់រងត្រូវបានបង្កឡើងដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬដោយផ្នែក ដោយសារព្រឹត្តិការណ៍ណាមួយដូចខាងក្រោម៖

(១) ការធ្វើអត្តឃាតក្នុងរយៈពេល ២ (ពីរ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមសុពលភាពនៃបណ្ណសន្យារ៉ាប់រង។

(២) ការប្រព្រឹត្តិ ឬប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

(៣) វីរុសហ៊ីវ (HIV) និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ (HIV) ដែលរួមមានទាំងជំងឺអេដស៍ និង/ឬការបំលែង ការវិវត្តន៍ ឬការប្រែប្រួលនៃមេរោគអេដស៍។

(៤) ការប្រើប្រាស់ថ្នាំញៀន ឬថ្នាំភ្លេចអារម្មណ៍ ឬការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬផលវិបាកផ្សេងៗដូចដែលបានកំណត់ដោយច្បាប់ដែលបានចូលជាធរមាន។

**២. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**

ក្រុមហ៊ុនមិនធានាលើការបាត់បង់ឬពិការភាពដែលបណ្តាលមកពីព្រឹត្តិការណ៍ដែលកើតឡើងដោយផ្ទាល់ឬដោយប្រយោល ទាំងស្រុង ឬ ដោយផ្នែក ដោយសារព្រឹត្តិការណ៍ណាមួយដូចខាងក្រោម៖

(១) ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។

(២) ការឆ្លងវីរុសហ៊ីវ (HIV) រោគសញ្ញានៃជំងឺអេដស៍ ឬជំងឺដែលទាក់ទងនឹងជំងឺអេដស៍។

(៣) សង្គ្រាម (មិនថាបានប្រកាស ឬមិនបានប្រកាស) ការឈ្លានពាន សកម្មភាពលុកលុយរបស់សត្រូវបរទេស សង្គ្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ចលាចលស៊ីវិល ការធ្វើកុបកម្ម ការធ្វើកូដកម្ម ការបះបោរប្រឆាំងនឹងរដ្ឋាភិបាល និងអំពើភេរវកម្ម។

(៤) ខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងប្រព្រឹត្តបទឧក្រិដ្ឋ ឬខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងកំពុងត្រូវបានចាប់ខ្លួន ឬត្រូវរងការចាប់ខ្លួន ឬកំពុងរត់គេចពីការចាប់ខ្លួន។

(៥) ការធ្វើដំណើរចូល ការចាកចេញ ការធ្វើប្រតិបត្តិការបញ្ជា ការធ្វើប្រតិបត្តិការជួសជុលថែទាំ ឬត្រូវបានដឹកជញ្ជូនដោយយានឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាសនានា លើកលែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរបង់ប្រាក់ធម្មតា ឬអ្នកបម្រើការលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ពាណិជ្ជមួយ ដែលធ្វើប្រតិបត្តិការជាទៀងទាត់តាមកាលវិភាគ និងតាមគន្លងផ្លូវដឹកជញ្ជូនអ្នកដំណើរផ្លូវអាកាសដែលបានកំណត់ជាមុនរបស់ក្រុមហ៊ុន។

(៦) ខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងបំពេញកាតព្វកិច្ចជាយោធា ប៉ូលីស ឬជាអ្នកស្ម័គ្រចិត្តចូលរួមក្នុងសង្គ្រាម ឬការបង្ក្រាបឧក្រិដ្ឋកម្ម។

(៧) ស្ថានភាពដែលមានពីមុនស្រាប់មុនកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងមានសុពលភាព។ ស្ថានភាពដែលមានពីមុនស្រាប់ មានន័យថាជាជំងឺដែលអ្នកត្រូវបានធានារ៉ាប់រងបានដឹងច្បាស់ លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុន និងទទួលយកដោយក្រុមហ៊ុន។ អ្នកត្រូវបានធានារ៉ាប់រងអាចត្រូវបានចាត់ទុកថាបានដឹងច្បាស់អំពីស្ថានភាពដែលមានពីមុនស្រាប់ ប្រសិនបើមានស្ថានភាពណាមួយដូចបានចែងខាងក្រោម៖

- ក) អ្នកត្រូវបានធានារ៉ាប់រងបានទទួល ឬកំពុងទទួលការព្យាបាល
- ខ) យោបល់វេជ្ជសាស្រ្ត ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្រ្តត្រូវបានណែនាំ
- គ) មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ ឬ
- ឃ) វត្តមាននៃស្ថានភាពនោះអាចមើលឃើញដោយបុគ្គលធម្មតាក្នុងកាលៈទេសៈណាមួយ។

(៨) អ្នកត្រូវបានធានារ៉ាប់រងស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយ លើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។

(៩) ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីព។

ចំណាំ៖ ខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិត សូមអាន ខ និងលក្ខខណ្ឌធានារ៉ាប់រង។ ក្នុងករណីដែលកើតមានភាពមិនស៊ីចង្វាក់គ្នា ត្រូវយក ខ និងលក្ខខណ្ឌធានារ៉ាប់រងជាគោល។

## ទំនាក់ទំនងមកកាន់យើងខ្ញុំ

023-989-218 / 098-989-218

service@gc-life.com.kh www.gc-life.com.kh

វីនផាក ផ្ទះលេខ A១២ ផ្លូវR៨ ភូមិ ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ
រាជធានីភ្នំពេញ